# កំណត់ហេតុបូកសរុបនៃសម័យប្រជុំលើកទីមួយនៃការចរចា

## ស្តីពី

## អនុសញ្ញាស្តីពីបត្យាប័ន និង អនុសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមក ផ្នែកតុលាការក្នុងវិស័យព្រហ្មទណ្ឌ

## រវាង

## រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង

ចាប់ពីថ្ងៃទី ១០ ដល់ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ សម័យប្រជុំលើកទីមួយនៃការចរចាស្តីពីអនុសញ្ញាស្តីពីបត្យាប័ន និងអនុសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកតុលាការក្នុងវិស័យព្រហ្មទណ្ឌ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំងបានប្រព្រឹត្តធ្វើនៅរាជធានីភ្នំពេញក្នុងបរិវេណនៃក្រសួងយុត្តិធម៌។

គណៈប្រតិភូកម្ពុជាដឹកនាំដោយឯកឧត្តម **ហ៊ី សោភា** រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌។ បញ្ជីឈ្មោះនៃគណៈប្រតិភូកម្ពុជាមានភ្ជាប់ជាឧបសម្ព័ន្ធនៃកំណត់ហេតុនេះ។

គណៈប្រតិភូបារាំងដឹកនាំដោយលោក **ព្យែរ-គ្រីស្យង់ សូកូហ្សា** (Pierre-Christian SOCCOJA) ប្រធាននាយកដ្ឋានអនុសញ្ញា កិច្ចការរដ្ឋប្បវេណី និងការជួយគ្នាទៅវិញទៅមកផ្នែកតុលាការ នៃក្រសួងការបរទេស។ បញ្ជីឈ្មោះនៃគណៈប្រតិភូបារាំងមានភ្ជាប់ជាឧបសម្ព័ន្ធនៃកំណត់ហេតុនេះ។

ការចរចាបានប្រព្រឹត្តទៅក្នុងបរិយាកាសដ៏ល្អប្រសើរ ប្រកបដោយលក្ខណៈមិត្តភាព និងកិច្ចសហប្រតិបត្តិការ។

គណៈប្រតិភូទាំងពីរ បានចាប់ផ្តើមការចរចា ដោយធ្វើការពិនិត្យពិភាក្សាលើខ្លឹមសារនៃមាត្រាទាំងអស់នៃសេចក្តីព្រាងអនុសញ្ញាស្តីពីបត្យាប័ន។

បន្ទាប់មកទៀត គណៈប្រតិភូទាំងពីរបានពិនិត្យពិភាក្សាលើខ្លឹមសារចាប់ពីមាត្រា ១ ដល់មាត្រា ១១ និងមាត្រា ១៥ នៃសេចក្តីព្រាងអនុសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកតុលាការក្នុងវិស័យព្រហ្មទណ្ឌ។

សេចក្តីព្រាងនៃអនុសញ្ញាទាំងពីរ ដែលជាលទ្ធផលនៃការពិភាក្សានៅពេលបញ្ចប់សម័យប្រជុំលើកទីមួយនេះ មានភ្ជាប់ជាឧបសម្ព័ន្ធនៃកំណត់ហេតុនេះ។ បទប្បញ្ញត្តិនានាដែលមិនទាន់បានសម្រេច និងជាកម្មវត្ថុនៃការបន្តពិភាក្សាគ្នាក្នុងពេលខាងមុខ ត្រូវបានដាក់ក្នុងរង្វង់ក្រចកនៅក្នុងសេចក្តីព្រាងទាំងពីរ ដែលមានភ្ជាប់ជាឧបសម្ព័ន្ធ ជាភាសាខ្មែរ និងជាភាសាបារាំង។

ភាគីបារាំងសន្យាបញ្ជូនក្នុងពេលខាងមុខឲ្យភាគីកម្ពុជាតាមផ្លូវទូតនូវឯកសារពន្យល់នានាតាមសំណើសុំរបស់ភាគីកម្ពុជានាពេលប្រជុំពិភាក្សា។

នៅពេលបញ្ចប់សម័យប្រជុំលើកទីមួយនេះ គណៈប្រតិភូបារាំងបានអញ្ជើញគណៈប្រតិភូកម្ពុជាទៅទីក្រុងប៉ារីស ដើម្បីធ្វើការចរចាបន្តទៀត (ពិនិត្យពិភាក្សាបន្តលើមាត្រាដែលនៅសល់មិនទាន់ពិភាក្សានៅក្នុងអនុសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកតុលាការក្នុងវិស័យព្រហ្មទណ្ឌ និងរាល់បទប្បញ្ញត្តិដែលនៅសល់មិនទាន់សម្រេច) នៅកាលបរិច្ឆេទដែលត្រូវកំណត់តាមការព្រមព្រៀងគ្នារវាងភាគីទាំងពីរក្នុងពេលអនាគត ហើយពេលវេលាដែលសមស្រប គឺក្នុងអំឡុងពេល ៦ ខែខាងមុខនេះ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣

**តំណាងគណៈប្រតិភូកម្ពុជា**

ឯកឧត្តម **ហ៊ី សោភា**

**តំណាងគណៈប្រតិភូបារាំង**

លោក **ព្យែរ-គ្រីស្ទង់ សូកូហ្សា**

M. Pierre-Christian SOCCOJA